# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា
## ជម្រាបជូន
## លោកវេជ្ជបណ្ឌិត គួច ម៉េងលី

**កម្មវត្ថុ:** ការឆ្លើយតបចំពោះការបកស្រាយរបស់ លោកវេជ្ជបណ្ឌិត គួច ម៉េងលី។

**យោង :**
- លិខិតរបស់គណៈវិជ្ជាជីវៈសុខាភិបាល ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៦ ស្តីពីការសុំឲ្យកែតម្រូវអត្ថបទដែលបានចុះផ្សាយលើទំព័រកាសែតភ្នំពេញប៉ុស្តិ៍ និងនៅលើគេហទំព័ររបស់ភ្នំពេញប៉ុស្តិ៍ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ ផ្ញើជូន លោកវេជ្ជបណ្ឌិត គួច ម៉េងលី ។
- លិខិតរបស់ លោកវេជ្ជបណ្ឌិត គួច ម៉េង លី ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៦ ឆ្លើយតបទៅនឹងសំណើរបស់គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា។

គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា បានទទួលរួចហើយលិខិតរបស់លោក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១៦ ឆ្លើយតបនឹងលិខិតរបស់គណៈវិជ្ជាជីវៈសុខាភិបាលចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦។ គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា បានពិនិត្យការបកស្រាយបំភ្លឺរបស់លោកដែលថា បទសម្ភាសរបស់លោកជាការបញ្ចេញមតិជាបុគ្គល ជាការរិះគន់ ក្នុងចេតនារួមចំណែកកែទម្រង់ ធ្វើឲ្យប្រសើរឡើងនៅក្នុងសង្គមកម្ពុជា ដោយគ្មានចេតនា បំផ្លើស បន្តុះបង្អាប់ ឬ ធ្វើឲ្យខូចកិត្តិយស សេចក្តីថ្លៃថ្នូររបស់គ្រូពេទ្យ និងវិជ្ជាជីវៈសុខាភិបាល ហើយថាលោកមិនបានសំដៅលើគ្រូពេទ្យទាំងអស់ថាអាក្រក់នោះទេ គឺគ្រូពេទ្យដែលលោកបានជួបប៉ុណ្ណោះ។

**គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា សូមជម្រាបជូនលោកថា៖**

១. គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា គោរពសិទ្ធិបញ្ចេញមតិរបស់ពលរដ្ឋគ្រប់រូប។

២. គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា ស្វាគមន៍ចេតនារបស់លោកក្នុងការចូលរួមចំណែកកែលំអ ប្រព័ន្ធសុខាភិបាល និងសេវាសុខភាពនៅកម្ពុជា។

៣. គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជានៅតែយល់ថា ការវាយតម្លៃជាសាធារណៈណាមួយដោយគ្មានមូលដ្ឋានច្បាស់លាស់ ដែលអាចនាំទៅដល់ការភាន់ច្រឡំ បង្កភាពច្របូកច្របល់ ក្នុងចំណោមសាធារណជន ដោយអ្នកវិជ្ជាជីវៈសុខាភិបាលណាម្នាក់ គឺជាការបំពានទៅលើក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈសុខាភិបាល។

៤. គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា នៅតែយល់ឃើញថា ទោះជាចេតនាក្តី អចេតនាក្តី ទង្វើរបស់លោកបានបង្កការខូចខាតដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលនៅកម្ពុជា និងរបស់

វិជ្ជាជីវៈសុខាភិបាលទាំងមូល។ ការខុចខាតនេះ គ្មានអ្វីអាចជួសជុលបាន ក្រៅពីការសុំទោសដោយសុទ្ធចិត្ត និងជាសាធារណៈនោះទេ។ ដូច្នេះគណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា នៅតែទាមទារឲ្យលោកសុំទោសជាសាធារណៈឲ្យស័ក្តិសមជាគ្រូពេទ្យដែលមានវិជ្ជាជីវៈ មានសីលធម៌មួយរូប។ គណៈគ្រូពេទ្យកម្ពុជានឹងរក្សាការទាមទារនេះនៅក្នុងកំណត់ត្រាប្រតិបត្តិវិជ្ជាជីវៈផ្ទាល់ខ្លួនរបស់លោក ដរាបណាលោកមិនទាន់បំពេញបានត្រឹមត្រូវ។

៥. គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា សូមជូននូវទិន្នន័យគ្រួសៗអំពីវឌ្ឍនភាពនៃស្ថានភាពសុខាភិបាលនៅកម្ពុជាសម្រាប់ជាជំនួយស្មារតី៖

- វិនាសកម្មពីអតីតកាលបានបំផ្លាញដល់ឫសគល់នូវហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ជាពិសេសធនធានមនុស្ស។ យើងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាលធនធានមនុស្សដើម្បីបម្រើសេវាជូនប្រជាពលរដ្ឋ។ បុគ្គលិកសុខាភិបាលរបស់យើង ទទួលបន្ទុកយ៉ាងធ្ងន់ក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋ ដែលមានតម្រូវការដ៏ច្រើនផ្នែកសុខភាព។ មកទល់ពេលនេះគ្រូពេទ្យកម្ពុជាមួយរូប ត្រូវទទួលបន្ទុកបម្រើប្រជាជនប្រមាណ ៥០០០ នាក់ ដែលជាបន្ទុកធ្ងន់ជាងគេបំផុត បើធៀបនឹងបណ្តាប្រទេសអាស៊ាន (៥.៥ដងធៀបនឹងប្រ៊ុយណេ ៧.៥ដងធៀបនឹងសាំងហ្គាពួរ ៣.៥ដងធៀបនឹងម៉ាឡេស៊ី ២.៥ដង ធៀបនឹងប្រទេសថៃ និងវៀតណាម ៦ដងធៀបនឹងហ្វីលីពីន ១.៥ដង ធៀបនឹងឡាវ និងស្មើគ្នាជាមួយឥណ្ឌូនេស៊ី)។ បើនិយាយពីបុគ្គលិកក្របខ័ណ្ឌផ្សេងទៀត (គិលានុបដ្ឋាក និង ឆ្មប) តួលេខនេះរឹតតែធ្ងន់ធ្ងរជាងនេះទៀត។
- ទោះបីជាយ៉ាងនេះក្តី ក៏វិស័យសុខាភិបាល សម្រេចបានជោគជ័យធំៗមួយចំនួនជាទីមោទនៈដូចជា៖ ការចាក់ថ្នាំបង្ការដែលជួយបង្ការជំងឺ និងកាត់បន្ថយអត្រាស្លាប់របស់កុមារបានយ៉ាងច្រើនបានលុបបំបាត់ជាស្ថាពរ ជំងឺគ្រុនស្វិតដៃជើង ជំងឺកញ្ជ្រិល ជំងឺតេតាណូសទ្រិត។ កម្ពុជាត្រូវបានទទួលស្គាល់ជាអន្តរជាតិថា ជាប្រទេសដែលសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍លើការកាត់បន្ថយអត្រាស្លាប់របស់កុមារ អត្រាស្លាប់របស់ម្តាយ និងអត្រាឆ្លងជំងឺអេដស៍ ដែលមិនមានប្រទេសច្រើនទេ ក្នុងពិភពលោកនេះអាចសម្រេចបាន។ អាយុរំពឹងរស់របស់ប្រជាជនកម្ពុជាបានឡើងពី ៥៤ឆ្នាំ នៅឆ្នាំ ១៩៩០ មក ៧៣ ឆ្នាំ នៅឆ្នាំ២០១៣ (តាមតួលេខរបស់អង្គការសុខភាពពិភពលោក)។
- លើផ្នែកពង្រឹងការគ្រប់គ្រងការប្រកបវិជ្ជាជីវៈវិញ យើងបាននិងកំពុងពង្រឹងគណៈវិជ្ជាជីវៈ រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងរៀបចំការអប់រំក្រមប្រតិបត្តិ ក្រមសីលធម៌ និងជំនាញបច្ចេកទេសបន្តក្នុងគោលដៅ បង្កើនប្រសិទ្ធភាពនៃការបម្រើសេវា និងកាត់បន្ថយជា អតិបរិមានូវបាតុភាពអសកម្មដែលកើតចេញពីការប្រតិបត្តិវិជ្ជាជីវៈ។
- ប្រជាពលរដ្ឋក្រីក្រអាចទទួលបានការព្យាបាលដោយមិនបាច់បង់ថ្លៃនៅតាមគ្រឹះស្ថានសុខាភិបាលសាធារណៈតាមរយៈមូលនិធិសមធម៌ និងយន្តការហិរញ្ញប្បទានផ្សេងទៀត ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល។

៦. គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជា លើកទឹកចិត្តឲ្យលោក ស្វែងយល់បន្ថែមពីស្ថានភាពពិតនៃវិស័យសុខាភិបាលកម្ពុជា ដើម្បីជាទុនគ្រប់គ្រាន់សម្រាប់ធ្វើការវាយតម្លៃ ដោយមានតុល្យភាព និងប្រកបដោយសុភនិច្ឆ័យ ដោយពិនិត្យមើលព្រៃទាំងមូល កុំមើលតែដើមឈើមួយដើម។

គណៈវិជ្ជាជីវៈសុខាភិបាលកម្ពុជាសង្ឃឹមថា លោកនឹងយកទិន្នន័យជំនួយស្មារតីនេះ និងឯកសារផ្សេងៗទៀតមកពិចារណា និងបំពេញនូវកាតព្វកិច្ចផ្នែកសីលធម៌ឲ្យបានត្រឹមត្រូវ ដើម្បីជាប្រយោជន៍ ដល់ការលើកកម្ពស់សុខភាពប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាព និងសេចក្តីថ្លៃថ្នូររបស់គ្រូពេទ្យយើង ដែលលោកចង់រួមចំណែកដូចដែលលោកបានប្រកាសក្នុងលិខិតបំភ្លឺរបស់លោក។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦

**គណៈគ្រូពេទ្យកម្ពុជា**
**ប្រធាន**

**សាស្ត្រាចារ្យ ឆា គ្រុយ**

**គណៈទន្តពេទ្យកម្ពុជា**
**អគ្គលេខាធិការ**

**ទន្តបណ្ឌិត ប្រាក់ ចណ្ណី**

**គណៈគិលានុបដ្ឋាកកម្ពុជា**
**ប្រធានស្តីទី**

**អ៊ុន សាន**

**គណៈឆ្មបកម្ពុជា**
**ប្រធាន**

**អ៊ិច រ៉ាដា**